# Living the Lotus

## *Buddhism in Everyday Life*

5
2026
VOL. 248


















## Rissho Kosei-kai of Chicago

**Living the Lotus**
**Vol. 248 (May 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីស្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។
អង្គការរីស្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីស្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# តើខ្ញុំអាចធ្វើអ្វីបាន?

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្សូកូសេកៃ

## ធម្មជាតិតាក់តែងមកឲ្យមនុស្សមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមកសោះ ហេតុអ្វីក៏បានទៅជា....

កម្លាំងរបស់យើងជាមនុស្សម្នាក់ៗពិតជាតូចហើយខ្សោយណាស់។ ប្រសិនបើគ្មានគុណសម្បត្តិខ្ពស់ជាងសត្វដទៃ( superiority) ដោយចេះប្រើប្រាស់ភាសាដើម្បីប្រាស្រ័យទាក់ទងគ្នានិងប្រើឧបករណ៍ ព្រមទាំងធ្វើសកម្មភាពជាក្រុមទេ មនុស្សនឹងមិនអាចជម្នះក្នុងការតស៊ូដើម្បីឲ្យអាចរស់រានមានជីវិតនៅក្នុងលោកនេះបានឡើយ។ មូលហេតុដែលគេហៅមនុស្សថាជាសត្វសង្គមក៏គឺដោយសារតែយើងជាមនុស្សធ្វើទំនាក់ទំនងគ្នា សហការជាមួយគ្នាឆ្ពោះទៅរកការកសាងសង្គមដ៏ល្អតលាស់និងល្អប្រសើរមួយដោយបំណងចង់ឱ្យមនុស្សគ្រប់រូបរស់នៅដោយសេចក្ដីសុខ។

ពីមុនខ្ញុំព្រះករុណាអាត្មាភាពបាននិយាយថា" ការរស់នៅដោយសុខដុមរមនាជាមួយនឹងអ្នកដទៃគឺជាអត្ថន័យនៃការកើតមកជាមនុស្សរបស់យើងទាំងអស់គ្នា" ទោះជាមើលពីទស្សនៈប្រវត្តិសាស្រ្តនៃជីវិតក៏បែបនេះដែរដូច្នេះខ្ញុំព្រះករុណាអាត្មាភាពជឿជាក់ថាមនុស្សជាតិយល់ដឹងពីអត្ថន័យនេះដោយសភាវគតិ។

ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សព្វថ្ងៃនេះ ដោយសារនិន្នាការនៃការកំណត់យកទស្សនៈតម្លៃសម្បទាផ្ទាល់ខ្លួនជាអាទិភាព ក៏មិនដឹងមនុស្សមួយចំនួនកំពុងជាន់ប្រាំងទៅលើការប្រស្រ័យទាក់ទង និងបំណងប្រាថ្នាចង់រាប់ អានអ្នកដទៃ ដែលជាលក្ខណៈធម្មជាតិរបស់មនុស្ស។ ទង្វើនេះហាក់ដូចជានាំមនុស្សទៅរកភាពឯកោដោយសាមីខ្លួនៗឯង ឬក៏ទៅរកការព្រងើយកន្តើយចំពោះអ្នកដទៃ ដែលបង្កើតជាបញ្ហាសង្គម ដូចជាការស្លាប់តែឯងឯកោជាដើម។ នៅក្នុងពិភពនៃកុមារក៏មិនមានករណីលើកលែងដែរ។យោលទៅតាមការស្ទង់មតិថ្មីៗនេះនៅប្រទេសជប៉ុនក្នុងចំណោមសិស្សបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យចំនួនកុមានិងយុវជនដែលធ្វើអត្តឃាតបានឈានដល់កម្រិតខ្ពស់ខណៈដែលអត្រាកំណើតកំពុងតែធ្លាក់ចុះ ដែលជាស្ថានភាពគួរឱ្យព្រួយបារម្ភ។

ដូចដែលវិទូខាងប្រវត្តិជីវសាស្រ្ត(Biohistory)

លោកស្រីណាកាមូរ៉ា យេកូ ឥឡូវនេះមនុស្សភា " បាននិយាយកាលពីជាងដប់ឆ្នាំមុនថាគច្រើនដែលខ្ញុំចង់ជួយយកអាសា គឺ " សិស្សសាលាបឋមសិក្សាផ្ញើសំបុត្រឬសារមកខ្ញុំដោយនិយាយថាពួកគេមានបញ្ហាក្នុងជីវិត កុមារ។គេ" មិនចង់រស់ទេ

(Ikiiki / March 2015) "។ ឬ មានកុមារជាច្រើនដែលធ្វើអត្តឃាតដោយ សារតែភាពឯកោគ្មានមិត្តភក្តិនៅសាលារៀន ដោយសារក្នុងគ្រួសារមានភាពរកាំរកូសមិនចុះសម្រុងគ្នាគេក៏មានការហត់នឿយចិត្តហើយទៅជាចង់ស្លាប់។ករណីនេះ នៅតែមានបន្តរហូតមកដល់សព្វថ្ងៃនេះ។

## ត្រូវសួរសំណួរអំពីមាគ៌ាជីវិតរបស់ខ្លួនឯងជារៀងរាល់ថ្ងៃ

ប្រសិនបើយើងធ្លាប់ជួបការលំបាក ឬមានក្តីបារម្ភយើងអាចយល់បានយ៉ាងងាយពីទុក្ខលំបាករបស់អ្នកដទៃ ហើយអាចគិតថា "អ្នកនោះកំពុងតែជួបការលំបាកណាស់"ដែរ ។ ក៏ប៉ុន្តែ ប្រសិនបើយើងមិនដែលបានជួបប្រទះនឹងការលំបាកដោយផ្ទាល់ខ្លួនៗឯងទេ ជារឿយៗយើងមិនអាចបង្ហាញសូម្បីតែចំណាប់អារម្មណ៍ចំពោះអ្នកនោះហើយចុះទម្រាំតែនៅពេលដែលមនុស្សម្នាក់មានការឈឺចាប់ខ្លាំងរហូតដល់ចង់ស្លាប់ទៅទៀត? ខ្ញុំព្រះករុណាអាត្មាភាពគិតថាមានមនុស្សតិចណាស់ដែលអាចយល់ពីអារម្មណ៍របស់អ្នកដែលកំពុងជួបប្រទះនឹងទុក្ខសោកនោះ។

ព្រះសង្ឃសមាធិហ្សេងព្រះគ្រូដូហ្គេង (Do gen Zenji) បានបង្រៀនថា "រៀនមាគ៌ាព្រះពុទ្ធគឺរៀនពីខ្លួនឯង" ។ ទោះបីជាយើងគិតថាយើងស្គាល់ខ្លួនឯងច្បាស់ក៏ដោយ ក៏តាមពិតទៅសូម្បីតែពីខ្លួនឯងក៏យើងគ្មានយល់ដែរ។ បើយើងមិនយល់ពីខ្លួនឯងផង តើយើងអាចយល់ពីអារម្មណ៍អ្នកដទៃដូចម្តេចបាន? ខ្ញុំព្រះករុណាអាត្មាភាពយល់ថាដូចជាពិបាកណាស់។ ដូច្នេះ ក្នុងពិភពលោកដែលយុវជនជាច្រើនមានអារម្មណ៍ថាជីវិតលំបាក តើយើងទាំង ឡាយមិនអាចជួយអ្វីគេបានទេឬ? ទេ មិនដូច្នេះទេ។មិនមែនទាល់តែសោះ។

អប់រំវិទូលោកសាស្ត្រាចារ្យម៉ូរី ស្ហីនហ្សៅ ( Shinzo Mori) បានចង្អុលបង្ហាញថា "មិនថាជីវិតមានការឈឺចាប់យ៉ាងណានោះទេ នៅលើផែនដីនេះគ្មានពរជ័យណាធំជាងការត្រូវបានផ្តល់'ជីវិត' មកឲ្យឡើយ។ ហើយអ្វីដែលអាចបញ្ជាក់ចំណុចនេះឱ្យច្បាស់គឺសាសនាដែលត្រឹមត្រូវពិត»។ លោកស្រីណាកាមូរ៉ា ឃេកុ (Keiko Nakamura) ដែលយើងបានរៀបរាប់មកពីមុននេះ មានបំណងមុះមត់ចង់ប្រាប់ទៅកុមារទាំងឡាយថា "ការពិតដែលអ្នករស់នៅមានជីវិតនៅពេលនេះ គឺជារឿងដ៏អស្ចារ្យណាស់" ។

ទោះជាយ៉ាងណាក៏ដោយគេតោងតែសង្កត់ធ្ងន់ទៅលើការពន្យល់ពីសារៈសំខាន់នៃការពិតនៃជីវិត ហើយវិទូប្រវត្តិជីវសាស្ត្ររូបនេះ និយាយថា "ប្រសិនបើយើងតាមដានស្នាមជើងដូនតាយើងឱ្យឆ្ងាយតាមដែលអាចធ្វើបាន យើងនឹងបានទៅដល់កោសិកាដែលបន្តផ្ជាប់មនុស្សម្នាក់ទៅនឹងមនុស្សម្នាក់ទៀតនៃដូនតាយើងពី 3.8 ពាន់លានឆ្នាំមុន" ដែលបង្ហាញឲ្យយើងចាប់ភ្លឹកថា "ខ្លួនយើងនិងអ្នកដទៃគឺតែមួយ" ហើយ "មនុស្សគ្រប់គ្នាគឺជាតែមួយ" ដែលផ្តល់ដល់យើងនូវទឹកចិត្តគោរពខ្លួនឯងនិងអ្នកដទៃ និងភាពក្លាហានក្នុងការរស់នៅ។

លោកស្រីបានពន្យល់ថាបើដូច្នេះអ្វីដែលសំ ខាន់បំផុតដំបូងគេបង្អស់គឺយើងជាមនុស្សធំត្រូវបង្ហាញរបៀបដែលយើងទទួលយកការលំបាកនៃជីវិតពីការចាប់ភ្លឹកទៅលើអំណរគុណដោយអាចរស់រានមានជីវិតឥឡូវនេះនិងតើត្រូវរស់នៅដោយរបៀបណាយោលទៅតាមជីវភាពរស់នៅជារៀងរាល់ថ្ងៃរបស់យើង។ ជាលទ្ធផល នៅពេលដែលឮសំឡេងនៃការរងទុក្ខនោះ យើងអាចផ្តល់នូវពាក្យលើកទឹកចិត្តនិងផ្តល់កម្លាំងដល់អ្នកមានទុក្ខសោកបាន។

ព្រះសង្ឃសមាធិZen ព្រះគ្រូRyokan បានមានសង្ឃដីកាថា ៖

«បើគេសួរថាតើអ្វីដែលអាក្រក់មើលនិងនាំឲ្យឈឺចាប់បំផុតត្រូវឆ្លើយថាគឺការរើសអើង ភាពក្រអឺតក្រទមនិងបេះដូងដែលឃ្លាតឆ្ងាយពីមនុស្សដោយសារតែមិនដឹងមិនយល់»។ការឈឺចាប់ដ៏ធំបំផុតគឺនៅពេលដែលមនុស្សមិនជួយគ្នា និងមិនចុះសម្រុងគ្នា។ ហេតុដូច្នេះហើយយើងគួរតែធ្វើការឆ្លុះបញ្ចាំងឬធ្វើស្វ៊ែត្រិះរិះពីរបៀបដែលយើងរស់នៅរាល់ថ្ងៃហើយយើងក៏គួរកត់សម្គាល់សូម្បីតែការផ្លាស់ប្តូរតិចតួចនៃអ្នកដែលរស់នៅជិតស្និទ្ធនឹងយើង ដោយសួរថា "តើអ្នកមិនអីទេឬ?" ផងដែរ ។ការធ្វើបែបនេះម្តងហើយម្តងទៀតអ្នកអាចនឹងជួយសង្គ្រោះមនុស្ស និងបានរួមចំណែកក្នុងការបណ្តុះបណ្តាលយុវជន

"កូសេ" ចេញផ្សាយខែឧសភាឆ្នាំ២០២៦




# A Global Buddhist Movement




Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)